ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

រដ្ឋបាលខេត្តកំពង់ធំ
ចូល
លេខ: ៤០០៦ ១១
ថ្ងៃទី ២០.១០.១៧ ម៉ោង
បញ្ជូនទៅ:

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តម និងលោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** : ស្តីពីការផ្សព្វផ្សាយសេចក្តីជូនដំណឹង ការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់លើកទី១០ របស់សាលាភូមិន្ទរដ្ឋបាល។

**យោង** : - លិខិតលេខ ៥៥៧ ស.ភ.រ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ របស់សាលាភូមិន្ទរដ្ឋបាល
- សេចក្តីសម្រេចលេខ ២០៣៩ មស.សសរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម និងលោកជំទាវ** មេត្តាជ្រាបថា សាលាភូមិន្ទរដ្ឋបាល នឹងរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីជាន់ខ្ពស់លើកទី១០ ចំនួន៦០នាក់ លើមុខជំនាញចំនួន៣សំខាន់ៗ រួមមាន៖

១.ជំនាញរដ្ឋបាលទូទៅ ចំនួន២០នាក់
២.ជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន២០នាក់
៣.ជំនាញទំនាក់ទំនងអន្តរជាតិ ចំនួន២០នាក់។

សម្រាប់ព័ត៌មានលម្អិត និងលក្ខខណ្ឌនៃការប្រឡងប្រជែងមានដូចខាងក្រោម៖

## I. លក្ខខណ្ឌក្នុងការដាក់ពាក្យ

បេក្ខជនទាំងពីរភេទត្រូវ៖

- កម្រិតសញ្ញាបត្រ ៖ ត្រូវមានសញ្ញាបត្រទាបបំផុតបរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។
- លក្ខខណ្ឌអាយុ ៖
  - បេក្ខជនជាមន្ត្រីរាជការ និងបេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីសញ្ញាបត្រថ្នាក់បណ្ឌិតឡើងទៅ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
  - បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ គិតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧
  - បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ គិតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧
- លិខិតថ្កោលទោស ៖ ត្រូវមានលិខិតថ្កោលទោស ចេញដោយក្រសួងយុត្តិធម៌ នៅក្រោយពេលប្រឡងជាប់ជាស្ថាពរ។

## II. វិញ្ញាសាប្រឡងប្រជែង

វិញ្ញាសាប្រឡងប្រជែងរួមមាន៖ វិញ្ញាសាសរសេរ និងវិញ្ញាសាសួរផ្ទាល់មាត់។

ក.វិញ្ញាសាសរសេរលើកទី១ មាន៖

| | | |
|---|---|---|
| - សំណួរពហុចម្លើយ | រយៈពេល ២ម៉ោង | មេគុណ១ |
| - ភាសាបារាំង ឬអង់គ្លេស | រយៈពេល ១ម៉ោង ៣០នាទី | មេគុណ១ |

មានតែបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរលើកទី១តែប៉ុណ្ណោះ ដែលនឹងត្រូវអនុញ្ញាតឱ្យចូលរួមប្រឡងវិញ្ញាសាសរសេរលើកទី២។

ខ.វិញ្ញាសាសរសេរលើកទី២ មាន៖

| | | |
|---|---|---|
| - អធិប្បាយពាក់ព័ន្ធនឹងចំណេះដឹងទូទៅ | រយៈពេល ៣ម៉ោង | មេគុណ៣ |
| - ដោះស្រាយបញ្ហាករណីសិក្សា | រយៈពេល ២ម៉ោង | មេគុណ១ |
| - ជំនាញ | រយៈពេល ៣ម៉ោង | មេគុណ៣ |

បេក្ខជនត្រូវជ្រើសរើសវិញ្ញាសាជំនាញរបស់ខ្លួនឯងដូចខាងក្រោម៖

១.សេដ្ឋកិច្ច-ហិរញ្ញវត្ថុ (សម្រាប់ជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

២.រដ្ឋបាលសាធារណៈ (សម្រាប់ជំនាញរដ្ឋបាលទូទៅ)

៣.នីតិអន្តរជាតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ (សម្រាប់ជំនាញទំនាក់ទំនងអន្តរជាតិ)

មានតែបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរលើកទី២ប៉ុណ្ណោះ ដែលនឹងត្រូវអនុញ្ញាតឱ្យចូលរួមវិញ្ញាសាសួរផ្ទាល់មាត់។

គ.វិញ្ញាសាសួរផ្ទាល់មាត់ ៖ ធ្វើមូលវិចារណ៍លើបុគ្គលិកលក្ខណៈ និងលើហេតុប្បវត្តិរបស់បេក្ខជនក្នុងពេលមួយសម្រាប់ រយៈពេលពី ១៥នាទី ទៅ៣០នាទី មេគុណ៣។

ចំពោះបេក្ខជនមានចំណាប់អារម្មណ៍ សូមចុះឈ្មោះចូលរួមប្រឡងប្រជែងតាមរយៈប្រព័ន្ធ Online តាមគេហទំព័រ sms.era.gov.kh ហើយផុតកំណត់ឈប់ទទួលពាក្យនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១៧:៣០ នាទី។ ចំពោះព័ត៌មានលម្អិតផ្សេងទៀត មាននៅលើគេហទំព័រ www.era.gov.kh ឬសូមទំនាក់ទំនងជាមួយការិយាល័យរដ្ឋបាល នៃសាលាភូមិន្ទរដ្ឋបាល ឬតាមរយៈទូរស័ព្ទលេខ ០១៧ ៨០៣ ៤២៦, ០៩៦ ៥៣៦៥ ៣៧៧, ០២៣ ६២២២ ២៦៦, ០៩៧ ៦៣២៧ ១៧៤។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម និងលោកជំទាវ** មេត្តាជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម និងលោកជំទាវ** មេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។៚

អគ្គលេខាធិការ

ថ្នាក់ សំអឿន

<u>ទំនាក់ទំនង៖</u>

លោក ងួន គឹមសេង

ទូរស័ព្ទលេខ: ០១១ ៣២២ ២២៧